# សារៈសំខាន់នៃឈើឆ្កាង



មានផ្លូវជាច្រើន ដើម្បីឆ្ពោះទៅកាន់ឈើឆ្កាង ប៉ុន្តែដើម្បីអោយបានទៅដល់ឈើឆ្កាង យើងត្រូវតែចូលមក! នេះគឺជាខ្លឹមសារដ៏សំខាន់នៃជំនឿគ្រិស្តបរិស័ទ ។ ប្រសិនបើមានមន្ទិលសង្ស័យ សូមអានពីគោលបំណងនៃព្រះជន្មរបស់ព្រះគ្រិស្ត និងផ្ទៃរឿងនៃកណ្ឌគម្ពីររ៉ូម ។ បទគម្ពីរនេះមានពោរពេញទៅដោយការបង្រៀនអំពីឈើឆ្កាង ។

ដូចជាកិច្ចការជាច្រើនទៀតដែរ ជាញឹកញាប់និមិត្តរូបនៃឈើឆ្កាងត្រូវបានគេមើលរំលង។ វាជារឿងសាមញ្ញពេលឃើញមានរូបឈើឆ្កាងពាក់នៅនឹងក ឬ ឈើឆ្កាងមួយដាក់នៅលើដំបូលនៃព្រះវិហារ។ ប៉ុន្តែនិមិត្តរូបនេះជាការបង្ហាញពីលទ្ធផលនៃការសុគត និងការរស់ឡើងវិញរបស់ព្រះយេស៊ូដែលយើងអាចស្គាល់ព្រះជាម្ចាស់បានតាមរបៀបផ្ទាល់ខ្លួន ។



*"ឥឡូវនេះ បើព្រះជាម្ចាស់ប្រោសយើងឲ្យសុចរិត ដោយសារព្រះលោហិតរបស់ព្រះគ្រិស្តយ៉ាងហ្នឹងទៅហើយ ព្រះអង្គរឹតតែសង្គ្រោះយើងឲ្យរួចពីព្រះពិរោធ ដោយសារព្រះគ្រិស្តថែមទៀតជាពុំខាន ។" រ៉ូម ៥:៩*

## គោលបំណងរបស់ឈើឆ្កាង

**១.	ការអត់ទោសបាប និងការដកចេញនូវការដាក់ទណ្ឌកម្ម ។**

មានរឿងព្រេងភាគប៉ែកលោកខាងកើត ដែលប្រាប់ពីព្រះអង្គម្ចាស់វ័យក្មេងមួយអង្គដែលទើបតែឡើងគ្រងរាជ្យលើបល័ង្គ។ ដែលពីមុនព្រះមាតាទ្រង់ជាអ្នកគ្រងរាជ្យ។ ព្រះនាងមានមោទនភាពនិងសព្វព្រះទ័យក្នុងការគ្រងរាជ្យ ទើបវាជាការពិបាកដែលត្រូវដាក់រាជ្យថ្វាយ ទៅក្នុងព្រះហស្តព្រះបុត្រារបស់ទ្រង់វិញ។ អ្វីៗមិនបានល្អប្រសើរសម្រាប់ព្រះបុត្រានោះទេ ។ អាថ៌កំបាំងរបស់ស្រុកទេសបានបែកធ្លាយ ធ្លាក់ទៅក្នុងកណ្តាប់ដៃរបស់ពួកខ្មាំងសត្រូវ ។ បន្ទាប់ពីរឿងនេះបានកើតឡើង ជាលើកទីពីរព្រះមហាក្សត្របានចេញព្រះរាជក្រឹត្យមួយថា បើអ្នកណាលួចក្បត់ដោយសំងាត់ត្រូវគេចាប់ បាន អ្នកនោះនឹងត្រូវធ្វើទារុណកម្មនៅទីប្រជុំជន ។

ជារឿងដែលគួរឲ្យសោកស្តាយសម្រាប់ព្រះមហាក្សត្រ ដ្បិតព្រះមាតាទ្រង់គឺជាពិរុទ្ធជន ។ ប្រជារាស្ត្រស្មានថាស្តេចនឹងមិនដាក់ទណ្ឌកម្មព្រះមាតាទ្រង់ទេ។ សវនាការបានដាក់ជាសាធារណៈនៅទីប្រជុំជន ត្រូវបានដំណើរការ។ ជាពេលថ្ងៃត្រង់ ច្រកទ្វារនៃព្រះបរមរាជវាំងត្រូវបានបើក មានស្ត្រីម្នាក់ក្រៀជាប់នឹងព្រះហស្តស្តេច។ ដូចជាការរំពឹងទុកពីតុលាការដែលចេញសាលក្រមថាព្រះនាងត្រូវមានទោស ។ ព្រះនាងត្រូវបានគេនាំទៅកាន់បង្គោលវាយប្រហារមួយ ប៉ុន្តែភ្លាមនោះស្តេច វ័យក្មេងនោះបានលោតពីរាជ្យបល្ល័ង្កឆ្ពោះទៅកាន់បង្គោលដែលគេវាយនោះ ឆ្អឹងខ្នងរបស់ស្តេចត្រូវបានបាក់បន្ទាប់ពីរងការវាយម្តងយ៉ាងដំណំ ។ នៅលើព្រះកាយស្តេចមានស្នាមឈាម ក្រោយមកស្តេចត្រូវបានគេយកទៅកាន់ព្រះរាជវាំង ដើម្បីជួយសង្គ្រោះព្យាបាលឡើងវិញ ។ (មិនស្គាល់ប្រភពអត្ថបទ)

ដោយសារតែព្រះជាម្ចាស់ ទ្រង់សុច្ចរិត អំពើបាប (ការធ្វើខុសដែលបំបែកយើងចេញពីការប្រកបជាមួយព្រះជាម្ចាស់) ត្រូវបានដោះស្រាយ ហើយការនេះអាចកើតមានឡើងបាន
ដោយការសុគតរបស់ព្រះគ្រិស្តដែលឥតមានបាបសោះ។ ជំនឿរបស់យើងនៅក្នុងសកម្មភាពរបស់ព្រះអង្គ បាននាំឱ្យយើងទទួលនូវការអត់ទោស ។

*...ហើយព្រះយេហូវ៉ាបានទម្លាក់អំពើទុច្ចរិត របស់យើងទាំងអស់គ្នាទៅលើ*

*ព្រះអង្គ។ អេសាយ ៥៣:៦*

ដូច្នេះ នៅចំពោះព្រះនេត្រព្រះជាម្ចាស់ តាមរយៈការសុគតរបស់ព្រះគ្រិស្តនៅលើឈើឆ្កាង យើងបាន «រាប់ជាសុចរិត» ទុកដូចជាយើងមិនដែលបានប្រព្រឹត្តអំពើបាបសោះ។ កិច្ចការនេះបានកើតឡើងដោយសារតែព្រះជាម្ចាស់បានទតឃើញ
ការដាក់ទណ្ឌកម្មរបស់យើងត្រូវបានបង់ថ្លៃលោះ ដោយសារការរងទុក្ខរបស់ព្រះរាជបុត្រារបស់ព្រះអង្គ ។

## ២. ជីវិតអស់កល្ប

*សូមអានយ៉ូហាន ៣:១៦*

*« រីឯខ្ញុំវិញ ខ្ញុំមក ដើម្បីឲ្យមនុស្សលោកមានជីវិត ហើយឲ្យគេមានជីវិតពេញ*

*បរិបូណ៌» ។ យ៉ូហាន ១០:១០*

នៅពេលមនុស្សម្នាក់
មានបទពិសោធពីជីវិតដែលមានព្រះគ្រិស្តគង់នៅជាមួយ
នោះគេក៏ទទួលបាននូវបទពិសោធន៍ «ជីវិតអស់កល្បជានិច្ច» ដែរ។

ជីវិតដែលទទួលបានឥឡូវនេះគឺបានដោយសារសេចក្ដីជំនឿ
ដែលនៅតែបន្តរហូតដល់
សេចក្ដីស្លាប់នៅលើផែនដីនេះកន្លងផុតទៅទើបអាចទទួលបានបទពិសោធន៍ពេញលេញរបស់ព្រះជាម្ចាស់នៅក្នុងជីវិតបន្ទាប់បាន ។

### អត្ថន័យ និងគោលបំណង នៃជីវិតអស់កល្បជានិច្ច

*“ យើងស្គាល់ច្បាស់នូវគម្រោងការដែលយើងបានគ្រោងទុកសម្រាប់អ្នករាល់គ្នា ជាគម្រោងការដែលផ្ដល់សេចក្ដីសុខសាន្តដល់អ្នករាល់គ្នា គឺមិនមែនឲ្យ*



*អ្នករាល់គ្នាត្រូវវេទនាទេ។ យើងនឹងផ្ដល់សេចក្ដីសង្ឃឹម និងអនាគតល្អឲ្យអ្នករាល់គ្នា ។យេរេមា ២៩:១១*

ព្រះជាម្ចាស់យកព្រះទ័យទុកដាក់យ៉ាងជិតស្និទ្ធ
អំពីការសង្គ្រោះរបស់លោកអ្នក ទាំងនៅក្នុងជីវិតនេះ
និងនៅក្នុងជីវិតខាងមុខទៀត។

## ៣. ការបរាជ័យ នៃពួកគ្រប់គ្រង និង ពួកមានអំណាច

អេភេសូរ ៦:១២ បង្ហាញថា យើងត្រូវបានព័ទ្ធជុំវិញ ដោយឥទ្ធិពលអរូបីដ៏អាក្រក់ទាំងឡាយដែលមើលមិនឃើញ ។

នៅក្នុងកណ្ឌគម្ពីរដានីយ៉ែល ជំពូក១០
លោកដានីយ៉ែលបានតមអាហារ និងអធិស្ឋាន
នោះមានទេវតារបស់ព្រះអម្ចាស់បានលេចមកឯលោក (ខ១១) ។
អស់រយៈពេល ២០ថ្ងៃ ទេវតា (កាព្រីយ៉ែល)
បានតយុទ្ធចូលមកលោកដានីយ៉ែល (ខ១៣)។
ជាពេលដែលមហាទេវតាមីកែលមួយទៀតលេចមកដើម្បីជួយទេវតាកាព្រីយែល អាចបំបែកកទេវតាចក្រភពពែរ្សចេញ ។ នៅក្នុង ខ ២០-២១ រៀបរាប់អំពីការតយុទ្ធមួយទៀត
ខណៈដែលលោកមានកិច្ចជួបមួយនៅពេលដែលលោកត្រឡប់មកវិញ ។

ជួនកាលកំឡាំងឥទ្ធិពលអាក្រក់ទាំងនេះ អាចលេចឡើង ។
* នៅលើប្រជាជាតិនានា *ដានីយ៉ែល ១០*
* នៅក្នុងមនុស្ស *ម៉ាថាយ ៨:១៦*
* នៅក្នុងវត្ថុនានា និងក្នុងសត្វណាមួយ ម៉ាកុស ៥:១២-១៣

សូមកុំភ័យខ្លាចវិញ្ញាណអាក្រក់ទាំងនេះឡើយ
ដ្បិតនៅលើឈើឆ្កាងបានយកឈ្នះលើពួកវាអស់ហើយ
ដូចដែលបានបញ្ជាក់រួចហើយដោយព្រះគ្រិស្តមានព្រះជន្មរស់ឡើងវិញ ។

សូមអាន កូល៉ុស ២:១៣-១៥
ដោយជំនឿ ចូរប្រកាសពីជ័យជម្នះនៅក្នុងព្រះនាមព្រះយេស៊ូ!

## ៤. អំណាចលើទំលាប់ដែលជាអំពើបាប

មនុស្សជាច្រើនត្រូវជាប់ចំណងដោយសារទំលាប់ដែលជាអំពើបាប។ បាប ដែលមិនអាចគ្រប់គ្រងបានដូចជា កំហឹង ចំណង់តណ្ហា

ភាពលោភលន់ និង ការចង់បានរបស់អ្នកដទៃ ។ល។ ជួនកាលវាក្លាយទៅជាទម្លាប់ច្រំដែលមួយដែលមនុស្សជាច្រើនមិនអាចកាត់ផ្តាច់បាន។ ប៉ុន្តែ សូមសរសើរតម្កើងព្រះ អម្ចាស់ ដ្បិតអំណាចបាបត្រូវបានកាត់ផ្តាច់តាមរយៈ ឈើឆ្កាងរបស់ព្រះគ្រិស្ត។

លោកប៉ូលបញ្ជាក់ពីការទទួលជ័យជម្នះនេះនៅក្នុង *រ៉ូម ៧:២៥* ។ មនុស្សជាច្រើនរាប់ពាន់នាក់ រួមទាំងខ្លួនខ្ញុំផ្ទាល់ក៏ធ្វើបន្ទាល់ពីជ័យជំនះនេះដែរតាមរយៈ ឈើឆ្កាងរបស់ព្រះយេស៊ូគ្រិស្ត មិនថាវាជា អំនួត ជាគ្រឿងស្រវឹង ឬជាគ្រឿងញៀននោះទេ។ គ្រាន់តែជឿ ហើយទទួលយកនូវជ័យជំនះនោះនៅក្នុងព្រះគ្រិស្តចុះ ដ្បិតការទាំងនេ បានសម្រេចរួចហើយ ។

## ៥. ការប្រោសអោយជា

ព្រះជាម្ចាស់នាំមកនូវការព្យាបាល តាមរយៈគ្រូពេទ្យ ការប្រើថ្នាំត្រឹមត្រូវ និងតាមរយៈការអធិស្ឋាន ដោយជំនឿ ។

*“ក្នុងចំណោមបងប្អូន បើនរណាមានជំងឺ ត្រូវអញ្ជើញព្រឹទ្ធាចារ្យរបស់ក្រុមជំនុំមកដើម្បីឲ្យលោកទាំងនោះអធិស្ឋានឲ្យគាត់ និងលាបប្រេង*ឲ្យក្នុងព្រះនាមព្រះអម្ចាស់។ ពាក្យអធិស្ឋានដែលផុសចេញមកពីជំនឿ នឹងសង្គ្រោះអ្នកជំងឺនោះ ហើយព្រះអម្ចាស់នឹងប្រោសគាត់ឲ្យក្រោកឡើងវិញ ប្រសិនបើគាត់បានប្រព្រឹត្តអំពើបាប ព្រះអង្គនឹងលើកលែងទោសឲ្យ។ ដូច្នេះ សូមបងប្អូនលន់តួបាបដល់គ្នាទៅវិញទៅមក ព្រមទាំងអធិស្ឋានឲ្យគ្នាទៅវិញទៅមកផង ដើម្បីឲ្យជាសះស្បើយ។ ពាក្យទូលអង្វររបស់មនុស្សសុចរិត*មានប្រសិទ្ធភាពខ្លាំងណាស់។” យ៉ាកុប ៥:១៤-១៦*

*សូមអាន អេសាយ ៥៣:៥*

វាហាក់ដូចជា រាល់អ្នកជំងឺដែលមករកព្រះយេស៊ូសម្រាប់ការប្រោសឲ្យជា គឺបានជាសះស្បើយមែន ។ ប៉ុន្តែក៏មានការចង្អុលបង្ហាញថា អ្នកដែលដើរតាមព្រះយេស៊ូមួយចំនួន នៅក្រុមជំនុំដើមមិនបានជាសះស្បើយនោះទេ។ សព្វថ្ងៃនេះក៏ដូចគ្នាដែរ វាដូចជាចម្ងល់មួយដែលថា ហេតុអ្វីបានជាមនុស្សខ្លះមានជំនឿខ្លាំង តែមិនបានជាពីជំងឺ បែជាអ្នកដែលមានជំនឿតិចបានជាពីជំងឺទៅវិញ ។ ជួនកាលមានគន្លឹះមួយដែលសំខាន់ សំរាប់ការប្រោសឲ្យជារបស់បុគ្គលម្នាក់ៗ នៅក្នុងការស្វែងរក និងរកឃើញនៅក្នុងការអធិស្ឋាន ។ ការប្រោសឲ្យជាអាចកើតមានឡើងឆាប់រហ័ស ឬបន្ទាប់ពីអស់ពេលជាយូរ ។ ប្រហែលជាតម្រូវអោយមាន ការអធិស្ឋានដោយជំនឿម្តងហើយម្តងទៀត។



ប៉ុន្តែពុំមានចម្លើយជាក់លាក់តែមួយនោះទេ សូម្បីតែគ្រិស្តបរិស័ទក៏ត្រូវបានគ្រាស់ហៅឱ្យឆ្លងកាត់នូវការសាកល្បងនៃជំងឺផងដែរ ។

# តើបុគ្គលម្នាក់អាចប្រោសអោយបានសុចរិត ដោយរបៀបណា?

សូមចងចាំថា ការប្រោសឲ្យបានសុចរិត គឺជាអ្វីដែលមកពីទស្សនៈរបស់ព្រះជាម្ចាស់ ដែលយើងត្រូវបាននាំមកក្នុងតំណែងមួយ «ដូចជាយើងមិនដែលធ្វើបាបសោះអញ្ចឹង» ។ ទាំងនេះកើតមានឡើងបានតាមរយៈកិច្ចការរបស់ព្រះគ្រិស្ត ដែលបានធ្វើនៅលើឈើឆ្កាង ។

## ១. ការទទួលនូវការប៉ះពាល់ចិត្តស្តីពីបាប

នេះមិនមែនជារឿងធម្មតានោះទេ ជាមួយនឹងវិប្បដិសារីពីទង្វើខុសឆ្គងមួយចំនួន ឬអារម្មណ៍សោកស្តាយចំពោះអំពើបាបដែលបានប្រព្រឹត្តកន្លងមក។ វាជាទុក្ខព្រួយដែលចេញពីការគោរពកោតខ្លាចព្រះជាម្ចាស់ ដែលនាំឱ្យមានការកែប្រែចិត្ត ជាបំណងចិត្តដ៏មុតមាំចង់បែរចេញពីអំពើបាបនោះ ។

*សូមអានលូកា ១៣:៣*

## ២. ការរាប់ជាសុចរិត តាមរយៈព្រះគ្រីស្ទ

ព្រះយេស៊ូមិនមែនគ្រាន់តែជាគ្រូបង្រៀនដ៏ល្អ និងជាអ្នកធ្វើការអស្ចារ្យតែម្នាក់នោះទេ ព្រះអង្គគឺជាព្រះ (យ៉ូហាន ២០:២៨) ។ តាមរយៈសេចក្តីសុចរិតរបស់ទ្រង់ (ព្រះជន្មដ៏ត្រឹមត្រូវឥតខ្ចោះរបស់ព្រះអង្គ) ទើបលោកអ្នកបានរាប់ជាសុចរិត ។

*សូមអាន រ៉ូម ៣:២២-២៤*

## ៣. តាមរយៈជំនឿលើព្រះគ្រិស្ត

ដោយការខិតខំប្រឹងប្រែងរបស់យើង នោះមិនមែនជាជំនឿនោះទេ ទោះបីជាសេចក្តីជំនឿរបស់យើងក៏ដោយ ប៉ុន្តែមានតែនៅក្នុងព្រះជាម្ចាស់ប៉ុណ្ណោះ ។

*សូមអានរ៉ូម ៤:៣*

ជាលទ្ធផលនៃការប្រែចិត្ត និងជំនឿលើព្រះគ្រិស្ត នៅពេលដែលយើងធ្វើការប្ដេជ្ញាចិត្តយកព្រះអង្គធ្វើជាម្ចាស់លើជីវិតរបស់យើង ហើយសុំការអត់ទោសនូវទង្វើ ខុសឆ្គងរបស់យើង នោះយើងនឹងបានរាប់ជាសុចរិត។

ការដាក់ទណ្ឌកម្មដោយខ្លួនឯង ឬ ការខិតខំដើម្បីឲ្យបានសង្គ្រោះដោយខ្លួនឯង នោះនឹងមិនអាចទៅរួចនោះទេ។ ប៉ុន្តែដើម្បីទទួលយក និងចុះចូលចំពោះកិច្ចការរបស់ព្រះគ្រិស្តដែលបានសម្រេចនៅលើឈើឆ្កាង ដែលជាលទ្ធផលយ៉ាងធំធេងមួយ គឺជីវិតអស់កល្បជានិច្ច សេរីភាព ការអត់ទោស និងក្ដីស្រឡាញ់ដ៏ពិត ។ គ្មានអ្វីគួរឱ្យឆ្ងល់នោះឡើយដែល «ដំណឹងល្អ» ជាអត្ថន័យនៃដំណឹងល្អនោះ! ។